ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១២៥/១៧ គ.ជ.ប.ក

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

ជាទីគោរពដ៏ខ្ពង់ខ្ពស់

## របាយការណ៍

**ស្តីពីកិច្ចប្រជុំធមាសទី១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

ដែលប្រព្រឹត្តទៅ នាថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ

កិច្ចប្រជុំធមាសទី១ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រព្រឹត្តទៅក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងមានការចូលរួមពីឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងមន្ត្រីជាន់ខ្ពស់ តំណាងក្រសួង និងអង្គភាពជំនាញជា សមាជិក គ.ជ.ប.ជ ចំនួន៥៨នាក់(ស្រី១៩នាក់) (មានជូនភ្ជាប់មកជាមួយនូវបញ្ជីវត្តមាន)។

របាយការណ៍ បានឆ្លុះបញ្ចាំងពីសភាពការណ៍ ប្រែប្រួលក្នុង៦ខែដើមឆ្នាំ ២០១៧ រួមមានការលេចឡើងនូវអំពើល្មើសដែលសង្ស័យថាជាអំពើជួញដូរសរីរាង្គ និងការជួញដូរទារក តាមអំពើអន្តរការីនៃការពរពោះជំនួស តែត្រូវបានបង្ក្រាបទាន់ពេល និងបន្តធ្វើការស៊ើបអង្កេត និងចាត់វិធានការបន្ថែមទៀត ធ្វើឲ្យស្ថានភាពបានស្ងប់ស្ងាត់ទៅវិញ ។

លើសពីនេះទៅទៀត បញ្ហាលំហូរកម្លាំងពលកម្មទេសន្តរប្រវេសន៍រហូតដល់ជាងមួយលាននាក់ ដែលកំពុងរស់នៅ និងធ្វើការងារនៅប្រទេសក្រៅ ជាពិសេសនៅប្រទេសថៃ គឺជាចំណុចដែលគួរចាប់អារម្មណ៍ ។ ក្នុងនោះ ស្ទើរតែចិត្តសិបភាគរយ មិនបានទៅតាមប្រព័ន្ធស្របច្បាប់ដែលមានចែងក្នុងអនុស្សរណៈកម្ពុជា ថៃ ស្តីពីការបញ្ជូនពលករស្របច្បាប់ទៅធ្វើការនៅប្រទេសថៃ នោះឡើយ ។ ការដោះស្រាយភាពស្របច្បាប់នៅក្នុងប្រទេសថៃ មានភាពស្មុគស្មាញ និងមិនមានផលចំណេញដល់កម្ពុជាឡើយ ពោលគឺ ថៃបានប្រមូលចំណូលទាំងស្រុង ពីពលករ រាប់លាននាក់ ហើយនៅតែជាភាពស្របច្បាប់បណ្តោះអាសន្ន ដែលធ្វើឲ្យពលករប្រឈមមុខដដែល ។ ពលករអាចរកកម្រៃបាន តែត្រូវចាយវាយទៅវិញស្ទើរទាំងអស់ក្នុងប្រទេសថៃ ហើយ

លទ្ធផលចុងក្រោយ គឺភាពចាស់ ជរា ពិកា សេពគ្រឿងញៀន និងការផ្លាស់ប្តូរឥរិយាបទ និងការបោះបង់កុមារ ឲ្យកំព្រា ខ្វះភាពកក់ក្តៅ ខ្វះការអប់រំ និងវិលទៅរកការផ្សងព្រេងដដែល ។

របាយការណ៍ ប្រមូលបានពីក្រុមការងារអន្តរក្រសួងទាំង៦ និងខេត្តចំនួន ២៣ (នៅខ្វះ ខេត្តមណ្ឌលគីរី និងខេត្តកំពង់ស្ពឺ) បង្ហាញថា មានការកើនឡើងនូវសកម្មភាពបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ ដោយប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៦ គឺ ៦៦/២៩ករណី ។

ឯការផ្តន្ទាទោស ក៏មានរបាយការណ៍ទាន់ពេល ទោះបីមិនទាន់គ្រប់ជ្រុងជ្រោយក៏ដោយ ។ ការបង្ការទប់ស្កាត់ គឺបានធ្វើឡើងយ៉ាងសកម្ម ជាពិសេស ការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព ដែលអាចឲ្យមនុស្សជាងពីរលាននាក់ បានដឹងឮពីរឿងជួញដូរមនុស្ស ផលប៉ះពាល់ និងការបង្ការទប់ស្កាត់ ។ តែភាពប្រថុយប្រថានធ្វើទេសន្តប្រវេសន៍ នៅតែកើនឡើង និងប្រឈមនឹងភាពរងគ្រោះឥតឈប់ឈរ ដែលជាបន្ទុករបស់រាជរដ្ឋាភិបាល ។ ពលករអាចរកកម្រៃបាន តែត្រូវចាយវាយទៅវិញស្ទើរទាំងអស់ក្នុងប្រទេសថៃ ហើយលទ្ធផលចុងក្រោយ គឺភាពចាស់ ជរា ពិកា សេពគ្រឿងញៀន និងការផ្លាស់ប្តូរឥរិយាបទ និងការបោះបង់កុមារ ឲ្យកំព្រា ខ្វះភាពកក់ក្តៅ ខ្វះការអប់រំ និងវិលទៅរកការផ្សងព្រេងដដែល ។

ចំពោះការជួយជនរងគ្រោះ ឬដោះស្រាយបញ្ហាពលករដែលត្រូវបានបញ្ជូន ចេញ ចូលឆ្លងកាត់ព្រំដែន រាជរដ្ឋាភិបាល មិនទាន់មានជម្រកបណ្តោះអាសន្នសមរម្យ ដែលអាចផ្តល់សេវាបឋម និងបានអប់រំ ណែនាំពលករ ដើម្បីបានយល់អំពីគោលជំហរ និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយ ភាពរងគ្រោះរបស់ពលករ នៅឡើយ ដែលធ្វើឲ្យពលករ ថ្នាំងថ្នាក់ជាមួយរាជរដ្ឋាភិបាល ។ សម្តេច ក្រឡាហោម ស ខេង ផ្តល់អនុសាសន៍ថា មិនគួររង់ចាំថៃ ឲ្យសាងសង់ទេ ព្រោះប្រើពេល ជិត១០ឆ្នាំមកហើយ មិនទាន់មានដំណើរការនៅឡើយ ។

អង្គប្រជុំ បានឯកភាពទៅលើរបាយការណ៍ និងទិសដៅដែលបានកំណត់ ។ ទោះបីជាយ៉ាងនេះក្តី សម្តេច ក្រឡាហោមស ខេង ប្រធាន គ.ជ.ប.ជ បានដាស់តឿន ឲ្យមានការទទួលខុសត្រូវខ្ពស់ លើ សភាពការណ៍បច្ចុប្បន្ន ដែលចាំបាច់ត្រូវដោះស្រាយភាពស្របច្បាប់ជូនពលករកម្ពុជា ដែលប្រឈមនឹងការបណ្តេញចេញ ពីប្រទេសថៃ ព្រោះតែខ្វះឯកសារស្របច្បាប់ បើទោះជាមានការពន្យាពេលអនុវត្ត វិធានការរឹតបន្តឹង ចំពោះពលករបរទេសខុសច្បាប់ តាមរយៈការចាប់បញ្ជូនចេញ ឬផាកពិន័យយ៉ាងធ្ងន់ធ្ងរ ទាំងថៅកែ ទាំងពលករខុសច្បាប់ក៏ដោយ ។

តាមការឯកភាព អនុសាសន៍ដឹកនាំរបស់សម្តេចក្រឡាហោម ដែលត្រូវដាក់បញ្ចូលក្នុងទិសដៅ និងត្រូវចាប់ផ្តើម អនុវត្តជាបន្ទាន់ ។ ចំណុចក្នុងគោលដៅបន្ថែមទាំងនោះ គឺះ

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងតំណាក់កាលនៃការជំរុញដោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់ ។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាន នៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល ។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម ។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ ដែលនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារទារក ការស្នាក់នៅបណ្តោះអាសន្ន មុនបានចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួលនិងភ្ជាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពពលករជាដើម ។

កិច្ចប្រជុំបានបញ្ចប់ទៅ ដោយមានការឯកភាពខ្ពស់ និងបរិយាកាសល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការ**

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ-ប៊ុនអេង**

បានឃើញ និងសូមគោរពជូន

**សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីជូនជ្រាប ដ៏ខ្ពង់ខ្ពស់**

**សម្តេចក្រឡាហោម ស ខេង**